# កំណែទម្រង់វិមជ្ឈការ និងការចូលរួមរបស់យុវជន ក្នុងអភិបាលកិច្ចមូលដ្ឋាននៅទីជនបទ

## សេចក្ដីផ្ដើម

មកទល់បច្ចុប្បន្ន កម្មវិធីវិមជ្ឈការតាមបែបប្រជាធិបតេយ្យនៅកម្ពុជា ដំណើរការបានជាងមួយទសវត្សរ៍ហើយ។ ការសម្រេចបានគោលដៅចម្បងៗក្នុងកម្មវិធីវិមជ្ឈការនៅកម្ពុជា កន្លងមកមានលទ្ធផលចម្រុះ (សូមមើលឯកសារ ដូចជា (jendal and Kim 2006; Kim and öjendal 2009; Kim 2012; Heng, Kim and So 2011; Heng and So 2012; Malena and Chhim 2009; EIC 2010; CDRI 2013)។ កំណែទម្រង់វិមជ្ឈការបានរួមចំណែកលើកកម្ពស់គោលការណ៍នយោបាយពហុបក្ស ដែលជាមូលដ្ឋានគ្រឹះនៃរបបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ឥឡូវនេះ ប្រជាជនអាចជ្រើសរើសថ្នាក់ដឹកនាំក្នុងមូលដ្ឋាន អាចចូលរួម ក៏ដូចជាបង្ហាញពីការចង់បាន និងតម្រូវការរបស់ខ្លួនក្នុងការអភិវឌ្ឍសហគមន៍។ ទោះជាយ៉ាងនេះក្ដី ការចូលរួមជាក់ស្ដែងរបស់ប្រជាជនក្នុងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតទាប ដោយសារក្រុមប្រឹក្សាឃុំ មិនមានលទ្ធភាពបំពេញតាមតម្រូវការក្នុងមូលដ្ឋាន, ការខ្វាយខ្វល់រកចិញ្ចឹមជីវិតប្រចាំថ្ងៃ, ទម្លាប់មានការរុញរា, បែបបទកោះអញ្ជើញឲ្យចូលរួម។ល។ ម្យ៉ាងទៀត ការចូលរួមក៏មានលក្ខណៈអសកម្ម និងជារឿយៗ តែងជំរុញឡើងដោយផលប្រយោជន៍ផ្ទាល់ខ្លួន ដែលចង់បានផលចំណេញភ្លាមៗ។

ទោះបីមានការស្រាវជ្រាវជាច្រើន ពិនិត្យពីការជំរុញរបស់វិមជ្ឈការទៅលើការចូលរួមរបស់ប្រជាជន ក្នុងការអភិវឌ្ឍ និងកិច្ចការនយោបាយនៅមូលដ្ឋានក្ដី ក៏នៅមិនទាន់មានការវាយតម្លៃជាលក្ខណៈប្រព័ន្ធណាមួយ ដែលផ្ដោតលើការចូលរួមរបស់យុវជននោះទេ។[១] ការសិក្សានេះព្យាយាមបំពេញចន្លោះខ្វះខាតក្នុងការសិក្សាកន្លងមក ដោយឆ្លើយតបនឹងសំណួរថា៖ តើយុវជនបានប្រើប្រាស់យ៉ាងណាដែរ នូវឱកាសដែលកំណែទម្រង់វិមជ្ឈការបានផ្ដល់ឲ្យ? លទ្ធផលសិក្សាផ្ដល់នូវការយល់ដឹងដ៏សំខាន់សម្រាប់ការពិភាក្សាអំពី ដំណើរការដែលវិមជ្ឈការបានក្លាយជាមធ្យោបាយជំរុញ ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅទីជនបទ។

## ការវាយតម្លៃពីការចូលរួមរបស់យុវជន

ការសិក្សានេះ វាយតម្លៃពីការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅតំបន់ជនបទ ដោយពិនិត្យលើសូចនាករធំៗបីខាងផ្នែកសង្គមនយោបាយ និងការបោះឆ្នោតដែលបង្កើតឡើងដោយមជ្ឈមណ្ឌលសម្រាប់ព័ត៌មាន និងការស្រាវជ្រាវពីការអប់រំ និងការអនុវត្តសិទ្ធិពលរដ្ឋ (CIRCLE 2002)។ សូចនាករនីមួយៗចែកជាសកម្មភាពជាច្រើន។ សូចនាករសង្គម រួមមាន ការស្ម័គ្រចិត្តជួយ ការងារអង្គការមិនទាក់ទងនឹងការបោះឆ្នោត, សមាជិកភាពសកម្មក្នុងក្រុម ឬអង្គការផ្សេងៗ, ការរៃអង្គាសមូលនិធិសម្រាប់សកម្មភាពសប្បុរសធម៌ និងការដោះស្រាយបញ្ហាសហគមន៍។ សូចនាករនយោបាយមានជាអាទិ ការជួបទាក់ទងជាមួយមន្ត្រីរាជការ, ការបញ្ជូន ឬចុះហត្ថលេខាលើសារ ឬញត្តិត៉វ៉ា, ការជួបទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ, ការធ្វើបាតុកម្ម, ការធ្វើពហិកា និងការស្ទង់មតិ។ សូចនាករការបោះឆ្នោត រួមមាន ការបោះឆ្នោតជាទៀងទាត់, ការបញ្ចុះបញ្ចូលអ្នកដទៃ, ការចូលរួមក្នុងគណៈបក្សនយោបាយ និងការជួយឃោសនាឲ្យបេក្ខជន (ការពិភាក្សាលំអិតអំពីសូចនាករទាំងនេះ មានចុះក្នុងការសិក្សារបស់ Heng, Vong and Chheat 2014.)។

ដើម្បីរក្សាឲ្យការសិក្សានេះមិនធំហួសកម្រិត អាចគ្រប់គ្រងបាន ប៉ុន្តែអាចបង្ហាញពីការចូលរួមរបស់យុវជនកម្ពុជា ក្នុងអភិបាលកិច្ចមូលដ្ឋាននៅតំបន់ជនបទ ក្រុមស្រាវជ្រាវបានជ្រើសរើសសកម្មភាពពីរសម្រាប់សូចនាករនីមួយៗគឺ៖ ការស្ម័គ្រចិត្តជួយការងារអង្គការមិនទាក់ទងនឹងការបោះឆ្នោត និងសមាជិកភាពសកម្មក្នុងក្រុម ឬអង្គការផ្សេងៗសម្រាប់សូចនាករសង្គម, ការជួបទាក់ទងជាមួយមន្ត្រីរាជការ និងការចុះហត្ថលេខាលើញត្តិត៉វ៉ាសម្រាប់សូចនាករនយោបាយ, និងការបោះឆ្នោតជាទៀងទាត់ និងការជួយឃោសនាឲ្យបេក្ខជន សម្រាប់សូចនាករការបោះឆ្នោត។

ការសិក្សានេះ មិនបានពិនិត្យពីទម្រង់មិនធម្មតានៃការចូលរួម ដូចជា បាតុកម្មជាដើមទេ ព្រោះវាមិនសូវស្របនឹងបរិបទនយោបាយនៅកម្ពុជា។ អ្នកស្រាវជ្រាវនានា (រួមទាំង Chandler 1996, 2000; Martin 1994; Hughes 2009) បានលើកមតិថា ចលនាវប្បធម៌ និងសង្គម ដែលមានភាពសំខាន់ក្នុងការកៀងគរសកម្មភាពសង្គមនោះ គឺមិនសូវឃើញមានក្នុងសង្គមកម្ពុជាទេ ជាពិសេសក្នុងសម័យខ្មែរក្រហម ដែលបណ្ដាសមាគមជាប្រពៃណី និងទម្រង់ផ្សេងៗ នៃសកម្មភាពជាសមូហភាពបានបាក់បែកខ្ទេចខ្ទីអស់។ ក្នុងទសវត្សរ៍១៩៩០ និង២០០០ មានឯកសារបង្ហាញពីភស្តុតាងនៃការឃាត់ឃាំង និងការទប់ស្កាត់ដោយប្រើហិង្សាពីសំណាក់រដ្ឋាភិបាល ទៅលើចលនាដោយសន្តិវិធីផ្សេងៗខាងនយោបាយ និងសង្គម (Hughes 2009)។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះធ្វើឡើងពីខែកញ្ញា ២០១៣ ដល់កុម្ភៈ ២០១៤ នៅឃុំចំនួន៤ ក្នុងខេត្តបី គឺព្រៃវែង កំពង់ចាម និងបាត់ដំបង។ តំបន់សិក្សា បានជ្រើសយកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យធំៗ ដូចជា ភូមិសាស្ត្រ, វត្តមានសមាគមយុវជនក្នុងតំបន់, និងទំនាក់ទំនងមានស្រាប់ជាមួយមន្ត្រីមូលដ្ឋាន។ ការជ្រើសរើសតំបន់

អត្ថបទនេះ រៀបរៀងដោយ ហេង សីហា និង វង់ ម៉ាន់ ជាអ្នកស្រាវជ្រាវ កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ នៃវិទ្យាស្ថាន CDRI។
អត្ថបទនេះ ដកស្រង់ចេញពីការសិក្សារបស់ Heng, Vong and Chheat (2014)។ សូមឯកសារនេះថា៖ Heng Seiha and Vong Mun. 2014. “The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance.” *Cambodia Development Review* 18(3):14-17។

១ ការសិក្សានេះកំណត់និយមន័យរបស់ពាក្យយុវជនថាជាអ្នកមានអាយុចន្លោះពី១៨ទៅ៣០ឆ្នាំ។

សិក្សាមានគោលដៅ គូសបញ្ជាក់ពីការចូលរួមរបស់យុវជននៅមូលដ្ឋាន ជាជាង បង្កើតនូវករណីសិក្សាសម្រាប់ប្រៀបធៀបគ្នា។

វិធីសាស្ត្រស្រាវជ្រាវ រួមមាន ការពិភាក្សាតាមក្រុមស្នូល (FGDs) និងសម្ភាសន៍ពាក់កណ្ដាលរៀបរយ។ ដើម្បីស្រាវជ្រាវពីការយល់ឃើញរបស់យុវជន ដែលមានបទពិសោធន៍សង្គមខុសៗគ្នា ក្នុងឃុំនីមួយៗមានធ្វើ FGDs ពីរលើកគឺ មួយលើកជាមួយអ្នកស្ម័គ្រចិត្តក្នុងអង្គការយុវជន និងមួយលើកទៀតជាមួយយុវជនមិនមានចូលរួមក្នុងបណ្ដាញយុវជន ហើយក្នុងការពិភាក្សានីមួយៗ មានយុវជនពីបួនទៅប្រាំមួយនាក់ស្មើភាពគ្នាខាងយេនឌ័រមកចូលរួម។ សម្ភាសន៍បានធ្វើឡើងជាមួយបុគ្គល ៣៣នាក់ រួមមាន មេឃុំ និងក្រុមប្រឹក្សាឃុំ, មេភូមិ, យុវជននិងតំណាងអង្គការយុវជននៅមូលដ្ឋាន, ក៏ដូចជាថ្នាក់ដឹកនាំអង្គការយុវជនថ្នាក់ជាតិ និងស្ថាប័នរដ្ឋាភិបាលផ្នែកយុវជន។

ការសិក្សាយ៉ាងទូលំទូលាយលើឯកសារមានស្រាប់ ដូចជាសៀវភៅ, អត្ថបទសារព័ត៌មាន, របាយការណ៍ និងការសិក្សានានាបានផ្ដល់ជាទស្សនៈរួមមួយ នៃការយល់ឃើញតាមហេតុការណ៍ជាក់ស្ដែង និងតាមទ្រឹស្ដីអំពីការចូលរួមផ្នែកនយោបាយ និងភាពសកម្មរបស់យុវជន។ អង្កេតមួយចំនួនមានផ្ដល់ទិន្នន័យសំខាន់ៗស្ដីពីការចូលរួមរបស់យុវជននៅកម្ពុជា ហើយការសិក្សានេះសំដៅកសាងបន្តលើសំណុំទិន្នន័យទាំងនោះ ដើម្បីអាចផ្ដល់ការពណ៌នាកាន់តែលំអិតថែមទៀត។

ការសិក្សានេះ ព្យាយាមគូសបញ្ជាក់ពីបញ្ហាសំខាន់ៗដែលនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការស្រាវជ្រាវបន្ថែម និងជួយរួមចំណែកដល់ការជជែកវែកញែក ពីការរីកចម្រើនរបស់យុវជននៅកម្ពុជា។ ប៉ុន្តែវិធីសាស្ត្រប្រមូលទិន្នន័យ និងអ្នកផ្ដល់ព័ត៌មានគន្លឹះមានតិចនាក់ បានធ្វើឲ្យការសិក្សានេះមានកំហិតចម្បងមួយគឺកង្វះលទ្ធភាពក្នុងការបំបែកលំអិតទិន្នន័យ (ឧ. ទៅតាមយេនឌ័រ, ស្ថានភាពសេដ្ឋកិច្ច, ការអប់រំ, ទំនាក់ទំនងនយោបាយនិងទីតាំងភូមិសាស្ត្រ)។

## លទ្ធផលសិក្សា

លទ្ធផលសិក្សាបង្ហាញថា ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅទីជនបទជាទូទៅ និងជាពិសេសក្នុងការធ្វើផែនការអភិវឌ្ឍន៍គឺនៅមានកម្រិតនៅឡើយ។ សកម្មភាពដែលយុវជនចូលរួម តែងជំរុញឡើងដោយអន្តរការីផ្សេងៗ ដូចជាសមាគមយុវជន សមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិ។ ដូច្នេះគេអាចនិយាយបានថា ប្រសិនបើគ្មានអន្តរការីដើរតួនាទីនោះទេ យុវជននៅតែគ្មានសេចក្ដីក្លាហាន និងអសកម្មដដែល។

### *ការចូលរួមផ្នែកសង្គម*

យុវជននៅមានចំណេះដឹងតិចនៅឡើយអំពី អង្គការសហគមន៍ (CBOs) ឬសមាគមនៅមូលដ្ឋាន និងមានការចូលរួមស្រាលៗជាមួយអង្គការទាំងនោះ។ ប៉ុន្តែការងារស្ម័គ្រចិត្តជាទូទៅមានការចូលរួមច្រើនពីយុវជន។ ភាពអសកម្មជាទូទៅរបស់ CBOs ធ្វើឲ្យមេភូមិមានតួនាទីសំខាន់ក្នុងការកៀងគរយុវជនស្ម័គ្រចិត្ត (សម្រាប់ជួយសហគមន៍ និង/ឬ ផលប្រយោជន៍គណបក្ស)។ មូលហេតុផ្នែកសេដ្ឋកិច្ច វប្បធម៌ និងបុគ្គល នាំឲ្យមានកង្វះការចូលរួមទូលំទូលាយរបស់យុវជន ក្នុងក្រុមសហគមន៍ និងការងារស្ម័គ្រចិត្តផ្សេងៗ។ តម្រូវការប្រាក់ចំណូលខ្ពស់ជាងមុនបាននាំឲ្យយុវជនជាច្រើន ទៅធ្វើការនៅក្រៅសហគមន៍របស់ពួកគេ។ កង្វះទឹកចិត្តក្នុងការចូលរួម និងការរារាំងពីឪពុកម្ដាយធ្វើឲ្យការចូលរួមរបស់យុវជនកាន់តែមានឧបសគ្គឡើង ហើយកង្វះយន្តការគាំទ្រផ្សេងៗ គឺជាឧបសគ្គសម្រាប់យុវជនដែលចង់ចូលរួម ប៉ុន្តែមិនដឹងថាត្រូវចាប់ផ្ដើមយ៉ាងដូចម្ដេច។ គេរកឃើញថាអង្គការយុវជនជាកាតាលីករដ៏សំខាន់ សម្រាប់ការចូលរួមរបស់យុវជននៅក្នុងសង្គម។ ក្រុមដូចខាងលើនេះ បានជួយបង្កើនការយល់ដឹងរបស់យុវជនអំពីវប្បធម៌នយោបាយ និងផ្ដល់ឱកាសល្អសម្រាប់ការចូលរួមក្នុងសង្គម[២] ដែលទំនងជាកត្តាសម្រាប់សំគាល់អ្នកសកម្ម ចេញពីអ្នកមិនសូវសកម្ម។ ទំនាក់ទំនងល្អជាមួយអាជ្ញាធរឃុំសង្កាត់ សំខាន់ខ្លាំងណាស់សម្រាប់ដំណើរការនេះ។

### *ការចូលរួមខាងផ្នែកនយោបាយ*

កង្វះចំណាប់អារម្មណ៍ ការគោរព ភាពដាច់ឆ្ងាយ និងការភ័យខ្លាច គឺជាលក្ខណៈដែលកើតមានញឹកញាប់ក្នុងសង្គមកម្ពុជា និងមានឥទ្ធិពលក្នុងទំនាក់ទំនង រវាងរដ្ឋាភិបាល និងប្រជាជន។ ប៉ុន្តែសម្រាប់យុវជនមួយចំនួន អារម្មណ៍របស់ពួកគេចំពោះមន្ត្រីនៅមូលដ្ឋាន គឺគោរពច្រើនជាងខ្លាច ពីព្រោះអាជ្ញាធរឃុំអាចប្រឈមនឹងការបោះឆ្នោតទម្លាក់។ បរិយាកាសនយោបាយដែលបើកចំហឡើងឆ្លងតាមដំណើរការវិមជ្ឈការ មានន័យថា យុវជនអាចជះឥទ្ធិពលទៅលើការសម្រេចចិត្តនៅមូលដ្ឋាន តាមរយៈការប្រជុំជាសាធារណៈ (ប្រជុំក្រុមប្រឹក្សាឃុំនិងប្រជុំភូមិ) និងការជួបទាក់ទងក្រៅផ្លូវការជាមួយមន្ត្រីនៅមូលដ្ឋាន។ ប៉ុន្តែការប្រើប្រាស់សិទ្ធិទាំងនេះនៅមានកម្រិតនៅឡើយ ហើយអ្នកប្រើប្រាស់សិទ្ធិទាំងនេះ ច្រើនជាយុវជនពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ទោះបីកន្លងមកមិនទាន់ឃើញមានរបាយការណ៍ពី ការបដិសេធសំណើចូលរួមក្នុងប្រជុំក្រុមប្រឹក្សាឃុំយ៉ាងណាក៏ដោយ ក៏ការប្រជុំក្រុមប្រឹក្សាឃុំ គឺជាការប្រជុំមួយដែលតម្រូវឲ្យមានការយល់ព្រម។ ម្យ៉ាងទៀត នៅពេលយុវជនទៅចូលរួមប្រជុំភូមិ ពួកគេទៅក្នុងនាមជាតំណាងរបស់ឪពុកម្ដាយ។ តួនាទីជាបន្ទាប់បន្សំរបស់យុវជនបែបនេះ មានន័យថា សកម្មភាពធ្វើផែនការដោយមានការចូលរួម នៅតែជាកិច្ចការរបស់មនុស្សចាស់។ មានការខ្វែងមតិគ្នាអំពីបញ្ហាថា តើយុវជនគួរចូលរួមប្រជុំភូមិដែរឬទេ។ ទោះយ៉ាងនេះក្ដី មានករណីវិជ្ជមានខ្លះៗទាក់ទងនឹងក្រុមប្រឹក្សាឃុំដាក់បញ្ចូលគំនិត និងសកម្មភាពរបស់យុវជនទៅក្នុងផែនការឃុំ។ ចំណែកឯករណីទាក់ទងនឹងការជួបទាក់ទងក្រៅផ្លូវការជាមួយមន្ត្រីមូលដ្ឋាន និងការដាក់ញត្តិតវ៉ាវិញ គឺកម្រកើតមាន។

---

២ "ការចូលរួមក្នុងសង្គមជាដំណើរការឯកទិសដែលក្នុងនោះ យុវជនបង្កើនការយល់ដឹងពីពិភពនយោបាយ តាមរយៈទំនាក់ទំនងជាមួយមនុស្សពេញវ័យ និងប្រព័ន្ធផ្សព្វផ្សាយ។ ការចូលរួមខាងផ្នែកនយោបាយ ជាដំណើរការមួយដែលប្រជាជនអាចកសាងឥរិយាបថ, គុណតម្លៃ, ជំនឿនិងមតិយោបល់ដែលជួយឲ្យពួកគេក្លាយជាពលរដ្ឋល្អនៅក្នុងប្រទេស ... វាជាប្រភេទជាក់លាក់មួយនៃការរៀនសូត្រផ្នែកនយោបាយ ដែលជួយឲ្យប្រជាជនកសាងនូវឥរិយាបថ, គុណតម្លៃ, ជំនឿ, មតិយោបល់និងអាកប្បកិរិយាអំណោយផលដល់ការក្លាយខ្លួនជាពលរដ្ឋល្អនៅក្នុងប្រទេស" (Anon. 2012)។

### *ការចូលរួមបោះឆ្នោត*

ការសិក្សានេះបង្ហាញថា យុវជនជាទូទៅចាប់អារម្មណ៍ខ្លាំងនឹងការបោះឆ្នោត ដោយមើលឃើញថាជាសិទ្ធិ និងការទទួលខុសត្រូវក្នុងការជ្រើសរើសអ្នកដឹកនាំល្អ និងជំរុញការអភិវឌ្ឍក្នុងសហគមន៍។ គេក៏សង្កេតឃើញដែរថា ការបោះឆ្នោតកំពុងក្លាយជាការពេញនិយមមួយ ដែលជាលទ្ធផលនៃការដើរតាមនិន្នាការសង្គម។ ទោះបីជាចំនួនយុវជនចុះឈ្មោះបោះឆ្នោតបានកើនឡើងគួរឲ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្តែយុវជនមិនបានទៅបោះឆ្នោតក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ពីរលើកចុងក្រោយនេះក៏មានអត្រាខ្ពស់ដែរ។ អត្រាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់វ័យក្មេង បានកើនពីប្រមាណ ១% ក្នុងឆ្នាំ២០០៧ ដល់ ៥% ក្នុងឆ្នាំ២០១២ ដែលជាការវិវត្តវិជ្ជមានមួយ ហើយសាធារណជនបានអបអរសាទរជាខ្លាំង។ ក្នុងការសម្រេចចិត្តបោះឆ្នោតឲ្យគណបក្សណាមួយនោះ យុវជនតែងមើលពីការរីកចម្រើនជាក់ស្តែងក្នុងការអភិវឌ្ឍនៅមូលដ្ឋាន, កម្មវិធីនយោបាយ និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ និងសមត្ថភាពរបស់បេក្ខជន ក្នុងការគោរពតាមពាក្យសន្យានៅពេលឃោសនាបោះឆ្នោត។ ព័ត៌មានទាំងនេះជ្រួតជ្រាបដល់សាធារណៈជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការបោះឆ្នោតជាចម្បង។ ប៉ុន្តែយុវជនត្រូវការព័ត៌មានច្រើនជាងនេះ ដើម្បីធ្វើការសម្រេចចិត្តឲ្យកាន់តែប្រសើរ។ ការបោះឆ្នោតជាសកម្មភាពប្រជាធិបតេយ្យមួយដែលមានប្រជាប្រិយភាព ប៉ុន្តែការចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត អាចជាបញ្ហារសើបមួយ ជាពិសេសសម្រាប់អ្នកស្ម័គ្រចិត្តក្នុងអង្គការយុជនដែលមានកាតព្វកិច្ចបំពេញការងារ ដោយមិនលំអៀងទៅខាងភាគីណាមួយស្របតាមគោលការណ៍របស់អង្គការខ្លួន ហើយក៏មិនចង់ធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងការងាររបស់ខ្លួន ជាមួយមន្ត្រីនៅមូលដ្ឋានដែរ។

### ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

ទោះបីកម្ពុជា បានអនុវត្តកំណែទម្រង់វិមជ្ឈការជាងមួយទសវត្សរ៍មកហើយក្តី ក៏ការចូលរួមរបស់ប្រជាជនជាទូទៅនៅមានកម្រិតទាប។ លទ្ធផលសិក្សានេះបង្ហាញថា ការចូលរួមរបស់យុវជនក៏នៅមានកម្រិតទាបដូចគ្នាដែរ។ ការចូលរួមកម្រិតទាបរបស់យុវជន ជាបញ្ហាមួយដែលត្រូវយកចិត្តទុកដាក់ខ្លាំង។ ការសិក្សានេះបង្ហាញទៀតថា គោលដៅកំណែទម្រង់វិមជ្ឈការដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងអភិបាលកិច្ចមូលដ្ឋានត្រូវប្រឈមជារឿយៗនឹងឧបសគ្គខាងនយោបាយ សេដ្ឋកិច្ចវប្បធម៌ និងរបស់បុគ្គលខ្លួនឯង។ ខាងផ្នែកនយោបាយ សកម្មភាពតិចតួចរបស់ក្រុមប្រឹក្សាឃុំ ដើម្បីជំរុញការចូលរួមរបស់យុវជនមានន័យថា ពួកគេដើរតួនាទីបន្ទាប់បន្សំបើធៀបនឹងអន្តរការីមិនមែនរដ្ឋាភិបាល។ តួយ៉ាងក្នុងចំណោមឃុំដែលក្រុមស្រាវជ្រាវបានចុះពិនិត្យ គ្មានឃុំណាមួយមានផែនការធ្វើឲ្យផែនការអភិវឌ្ឍន៍របស់ខ្លួនមានភាពទាក់ទាញដល់យុវជន និងជំរុញពួកគេឲ្យចូលរួមក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋានឡើយ។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍក្រុមយុវជនប្រហែលអាចកែលំអស្ថានភាពបច្ចុប្បន្ន ប៉ុន្តែនៅពេលនេះ សមាគមយុវជននានានៅមានតួនាទីសំខាន់បំផុត។

ទោះបីមានបញ្ហាជាច្រើន នៅរាំងស្ទះដល់ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅជនបទក្តី ក៏មានភស្តុតាងជាក់ស្តែង បង្ហាញពីការរីកចម្រើនទៅមុខជាបណ្តើរៗ ទោះបីជាមិនបានស្មើគ្នាល្អពីកន្លែងមួយទៅកន្លែងមួយក្តី។ ការសិក្សានេះមើលឃើញពីសារៈសំខាន់ នៃការប្រែប្រួលទិដ្ឋភាពនយោបាយនៅមូលដ្ឋាន ហើយបានធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោមទាក់ទងនឹងការរួមចំណែកនៃកំណែទម្រង់វិមជ្ឈការ ក្នុងការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅតំបន់ជនបទ។

ទី១ ការរួមចំណែកនៃកំណែទម្រង់វិមជ្ឈការ អាចមើលឃើញច្បាស់បំផុតនៅក្នុងដំណើរការបោះឆ្នោត។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ បានផ្តល់ឱកាសឲ្យយុវជនមានសមត្ថភាពក្លាយខ្លួនជាអ្នកតំណាងនៅមូលដ្ឋាន។ ម្យ៉ាងទៀតសំឡេងយុវជន ក៏កំពុងនិងបន្តមានសារៈសំខាន់ ក្នុងការកំណត់រចនាសម្ព័ន្ធអំណាចនយោបាយថ្នាក់មូលដ្ឋាន ពីព្រោះយុវជនមានចំណែកធំជាងគេក្នុងចំណោមប្រជាជនអ្នកបោះឆ្នោត (៣,៥៣លាននាក់ ឬ ៣៧% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោតសរុប ៩,៦៧លាននាក់ ក្នុងឆ្នាំ២០១២) (NEC 2012)។

ទី២ កំណែទម្រង់បានកែលំអទំនាក់ទំនងការងារ រវាងក្រុមប្រឹក្សាឃុំ អង្គការយុវជន និងអន្តរការីក្រៅរដ្ឋាភិបាលដទៃទៀត ដោយបានបង្កើតនូវ បរិយាកាសនយោបាយមូលដ្ឋានអំណោយផលដល់ការបណ្តុះវប្បធម៌នៃការចូលរួម។ ការសិក្សានេះទទួលស្គាល់នូវតួនាទីរបស់សមាគមយុវជន ដែលមិនត្រឹមតែជួយជំរុញការចូលរួមរបស់យុវជន នៅក្នុងសហគមន៍មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនចំណេះដឹងរបស់យុវជន អំពីភាពជាពលរដ្ឋ និងកិច្ចការនយោបាយ ព្រមទាំងបទពិសោធន៍ចូលរួមក្នុងសកម្មភាពសង្គម តាមរយៈការបណ្តុះបណ្តាល និងសកម្មភាពស្ម័គ្រចិត្តផ្សេងៗ។ ចាប់តាំងពីពេលបើកទូលាយប្រព័ន្ធនយោបាយនៅកម្ពុជានៅឆ្នាំ១៩៩៣មក អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានកើនចំនួនយ៉ាងច្រើន និងធ្វើប្រតិបត្តិការក្នុងទូទាំងប្រទេស ដើម្បីជំរុញការអភិវឌ្ឍ និងលទ្ធិប្រជាធិបតេយ្យ។ ក្រោយការអនុវត្តកំណែទម្រង់វិមជ្ឈការក្នុងឆ្នាំ២០០២ មានអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាច្រើនបានចូលរួមក្នុងសកម្មភាពផ្តល់សិទ្ធិអំណាចឲ្យប្រជាពលរដ្ឋ ដើម្បីឲ្យពួកគេទទួលបានអត្ថប្រយោជន៍ពីដំណើរការប្រជាធិបតេយ្យ និងកំណែទម្រង់វិមជ្ឈការ។ ក្នុងពេលជាមួយគ្នានេះ សមាគមយុវជនជាច្រើនបាននិងកំពុងធ្វើការនៅតាមមូលដ្ឋាន ដើម្បីបណ្តុះគំនិតទទួលខុសត្រូវក្នុងចំណោមយុវជន និងជួយពួកគេឲ្យកសាងអនាគតកាន់តែប្រសើរសម្រាប់ខ្លួនឯង និងសម្រាប់សហគមន៍។

ទី៣ ដំណើរការវិមជ្ឈការបានធ្វើឲ្យមានការកែសម្រួលជាបណ្តើរៗនូវទំនាក់ទំនង រវាងកុម្រប្រឹក្សាឃុំ នឹងយុវជន ពោលគឺមានការគោរពច្រើនឡើង និងការខ្លាចតិចជាងមុន។ ការប្រែប្រួលនេះផុសចេញពីការជួយសម្របសម្រួលដោយពួកអន្តរការី (ឧ. មេភូមិ, សមាគមយុវជន) និងការយល់ដឹងកាន់តែច្បាស់ពីតួនាទី និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាឃុំ ដែលត្រូវតំណាងផលប្រយោជន៍ និងបំពេញតាមតម្រូវការរបស់ប្រជាជន។ ចំណេះដឹងទាំងនេះ បង្កើតជាការរំពឹងទុកលើលទ្ធផលការងារ ដែលអាចដាក់សំពាធទៅលើអ្នកតំណាងឲ្យផ្តល់នូវលទ្ធផលគួរជាទីគាប់ចិត្តរបស់ប្រជាជន។

ផ្អែកលើការយល់ដឹងទទួលបានពីការសិក្សានេះ ក្រុមស្រាវជ្រាវសន្និដ្ឋានថា បញ្ហាប្រឈមនៃវិមជ្ឈការ គឺការជំរុញឲ្យយុវជនចូលរួមកាន់តែស៊ីជម្រៅ ក្នុងកិច្ចការសង្គម និងនយោបាយ។ ដំណើរការនៅគ្រប់កម្រិត ត្រូវសង្កត់ធ្ងន់លើតួនាទីរបស់អ្នកតំណាងជាប់ឆ្នោតនៅមូលដ្ឋាន និងសង្គមស៊ីវិល ដែលក្រុមស្រាវជ្រាវអះអាងថា អាចជួយពង្រីកឥទ្ធិពលនៃកំណែទម្រង់វិមជ្ឈការ តាមរយៈការដោះស្រាយឧបសគ្គផ្នែកវប្បធម៌ និងរបស់បុគ្គលផ្ទាល់ ដើម្បីសម្រួលការចូលរួម។ ការទទួលខុសត្រូវនេះ នឹងក្លាយជាបន្ទុកចម្បងរបស់ថ្នាក់ដឹកនាំនយោបាយ អ្នកកសាងគោលនយោបាយ និងថ្នាក់ដឹកនាំសង្គមស៊ីវិលដែលអាចជួយរៀបចំយុវជនជំនាន់ក្រោយ ឲ្យក្លាយជាធនធានដ៏សំខាន់សម្រាប់កម្ពុជាទៅថ្ងៃអនាគត។ ដំណើរការនេះមិនមែនងាយស្រួលទេ ប៉ុន្តែអនុសាសន៍ខាងក្រោមអាចជួយយុវជនឲ្យប្រើប្រាស់សក្តានុពលរបស់ខ្លួនយបានពេញលេញ និងចូលរួមយ៉ាងសកម្មក្នុងសង្គម។

## ការជួយមតិផ្នែកគោលនយោបាយ

វិធានការដែលអាចជំរុញឲ្យយុវជនចូលរួម កាន់តែផុសផុសក្នុងអភិបាលកិច្ចមូលដ្ឋាន គឺមានច្រើន ប៉ុន្តែមានបីសំខាន់ៗដែលគួរយកចិត្តទុកដាក់ជាពិសេស។

ទី១ បណ្តាស្ថាប័នរដ្ឋាភិបាលអ្នកកសាងគោលនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល គួរសិក្សាបន្ថែម ដើម្បីស្វែងយល់ពីសារៈសំខាន់នៃរដ្ឋបាលមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាជាក្តីបារម្ភរបស់យុវជន និងបញ្ហាផ្សេងទៀតក្នុងមូលដ្ឋានដែលប៉ះពាល់ដល់ពួកគេ។ ខាងក្រោមនេះ ជាប្រធានបទមួយចំនួនសម្រាប់ការស្រាវជ្រាវបន្ថែម៖

- ស្វែងយល់ពីបញ្ហាប្រឈម និងតម្រូវការរបស់យុវជន និងកំណត់ពីស្ថាប័នដែលអាចជួយដោះស្រាយ
- សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយបញ្ហា និងក្តីបារម្ភរបស់យុវជន
- សមត្ថភាពចាំបាច់ សម្រាប់ឲ្យក្រុមប្រឹក្សាឃុំដើរតួជាអ្នកតភ្ជាប់រវាងថ្នាក់លើនៃជួររដ្ឋាភិបាលនឹងយុវជន ដើម្បីផ្តល់ព័ត៌មានពីវិធីស្វែងរកឱកាសសិក្សា និងការងារ
- តើផែនការរបស់ក្រុមប្រឹក្សាឃុំមានចែងលំអិតគ្រប់គ្រាន់ និងជាប់ទាក់ទងដល់ស្ថានភាពរបស់យុវជន ឬទេ
- ទស្សនៈ និងឥរិយាបថ របស់យុវជនចំពោះផែនការរបស់ក្រុមប្រឹក្សាឃុំ និងកម្មវិធីនយោបាយរបស់គណៈបក្សនយោបាយ
- ឥទ្ធិពលនៃការអប់រំផ្លូវការ និងក្រៅផ្លូវការ ទៅលើការចូលរួមរបស់យុវជន
- ការសិក្សាកាន់តែមានលក្ខណៈជាប្រព័ន្ធ ស្តីពីឥទ្ធិពលនៃយេនឌ័រ ស្ថានភាពសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ ការអប់រំនិន្នាការនយោបាយ និងសាវតារគ្រួសារ ទៅលើការចូលរួមរបស់យុវជន។

ទី២ រដ្ឋាភិបាលគួរពន្លឿនការអនុវត្តគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍយុវជន ដែលបានអនុម័តនៅឆ្នាំ២០១១។[៣] ការអនុវត្តគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាព មិនត្រឹមតែផ្តល់ឲ្យយុវជន នូវ វេទិកាមួយដែលមានការទទួលស្គាល់ពីតួនាទីរបស់ពួកគេ និងអាចឲ្យពួកគេចូលរួមជាផ្លូវការក្នុងការអភិវឌ្ឍ និងការសម្រេចចិត្តផ្សេងៗ នៅក្នុងមូលដ្ឋាននោះទេ ប៉ុន្តែថែមទាំងជួយដោះស្រាយបញ្ហាប្រឈម (ដូចជា ការអប់រំ/ជំនាញកម្រិតទាប, ភាពអត់ការងារធ្វើ) ដែលរារាំងដល់ការចូលរួមរបស់យុវជនទៀតផង។

ទី៣ តួនាទីរបស់យុវជននៅក្នុងដំណើរការវិមជ្ឈការ គួរមានចែងដោយឡែកនៅក្នុងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (២០០៩)។ យុវជនកម្ពុជាមានតួនាទីសំខាន់ផ្នែកនយោបាយសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា ហេតុនេះ ការព្យាយាមជំរុញឲ្យយុវជន ចូលរួមជាផ្លូវការក្នុងការធ្វើវិមជ្ឈការ នឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍និងសង្គមជាតិទាំងមូល។

## ឯកសារយោង

Anon. 2012. "Political Culture and Socialization." In *21st Century American Government and Politics*, Section 6.2. Accessed 6 Oct 2014, http://2012books.lardbucket.org/books/21st-century-american-government-and-politics/s10-02-political-socialization.html.

CDRI. 2013. *Cambodia's Development Dynamics: Past Performance and Emerging Prioprities*. CDRI Special Report. Phnom Penh: CDRI.

Chandler, David. 1996. *Facing the Cambodian Past*. Bangkok: Silkworm.

Chandler, David. 2000. *A History of Cambodia*. Chiang Mai: Westview Press.

CIRCLE, Center for Information and Research on Civic Learning and Engagement. 2002. "Civic Engagement Indicators."Accessed 25 September 2013, www.civicyouth.org/ practitioners/Core_Indicators_Page.htm.

EIC, Economic Institute of Cambodia. 2010. *Report of the Second Citizen Satisfaction Survey in Target Communes of the LAAR Project*. Phnom Penh: EIC.

Heng Seiha, Kim Sedara and So Sokbunthoeun. 2011. *Decentralised Governance in Hybrid Polity: Localisation of D&D Reform in Cambodia.* Working Paper Series No. 63. Phnom Penh: CDRI.

Heng Seiha and So Sokbunthoeun. 2012. "Citizens' Perceptions of Their Responsibilities: Preliminary Analysis of D&D's Contribution to Reciprocial State-Society Relations in Battambang Province", 8-21. *Annual Development Review 2012-13*. Phnom Penh: CDRI.

Heng Seiha, Vong Mun and Chheat Sreang. 2014. *The Enduring Gap: Decentralisation Reform and Youth Participation in*

តទៅទំព័រ ២១

៣ គោលនយោបាយនេះ មានគោលដៅ "អភិវឌ្ឍយុវជនកម្ពុជាឲ្យមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ"។ យុទ្ធសាស្ត្រមួយនៅក្នុងគោលនយោបាយនេះ គឺលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងសហគមន៍មូលដ្ឋាន ស្ថាប័នផ្សេងៗ និងអង្គការសង្គមស៊ីវិល តាមរយៈយន្តការផ្លូវការ ដូចជា ការកំណត់ឲ្យមានតំណាងយុវជននៅក្នុងគណៈកម្មាធិការ និងក្រុមប្រឹក្សាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាដើម (MOEYS 2011, 2-5)។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៤៥% ធៀបនឹងអង្កេតលើកមុន ដល់ ៨៤៩៥រៀល។ កត្តាចម្បង គឺចំនួនកម្មករតិចជាងមុន ដែលធ្វើឲ្យប្រាក់កម្រៃកើនឡើងនៅខេត្តកំពង់ស្ពឺ និង កណ្ដាល។ ប្រហែល ៦៧% នៃកម្មករទាំងនេះ ក៏ត្រូវធ្វើការលើដីកសិកម្មរបស់ខ្លួនឯងដែរ ដែលមានទំហំប្រមាណ ០,១ ទៅ ១,៥ហិកតា ហើយអាចផ្ដល់នូវប្រាក់បន្ថែមពីលើចំណូលបានពីការលក់កម្លាំងពលកម្ម។ កសិករដែលគ្មានដីធ្លីត្រូវទ្រទ្រង់ជីវភាពគ្រួសារ ដោយប្រើប្រាស់ធនធានទ្រព្យរួមការចិញ្ចឹមមាន់ទា និងការខ្ចីបុល។ អ្នកស៊ីឈ្នួលធ្វើស្រែ ចំណាយ ២៩% នៃប្រាក់រកបាន ទៅលើម្ហូបអាហារ ដោយត្រូវធ្វើការជាមធ្យម ២៤ថ្ងៃ ក្នុងមួយខែ។

ចំណូលរបស់អ្នកលក់បន្លែ កើន ១៣% ដល់ ១៥.៣៧២ រៀល/ថ្ងៃ។ ក្នុងក្រុមនេះ មាន ៥៣% មកពីខេត្តកណ្ដាល ដូច្នេះអាចធ្វើដំណើរទៅមករៀងរាល់ថ្ងៃ។ សមាជិកក្រុមនេះ ៥៤% ស្នាក់នៅផ្ទះជួល ឬនៅជាមួយសាច់ញាតិ ឬនៅតាមវត្ត។ ពួកគេចាយវាយអស់ត្រឹមតែ ៣៩% នៃប្រាក់រកបានប៉ុណ្ណោះ ប៉ុន្តែប្រាក់ចំណូលតិចតួចនេះ នៅតែមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ អ្នកលក់បន្លែ ៧៥% ប្រាប់ថា ចង់ពង្រីកអាជីវកម្មខ្លួន ដើម្បីរកចំណូលបន្ថែម ប៉ុន្តែមិនមានលទ្ធភាពធ្វើ។

ចំណូលរបស់អ្នកបម្រើតាមភោជនីយដ្ឋាន កើន ១៣% ធៀបនឹងខែឧសភា ដល់ ៧៥៦៥រៀល/ថ្ងៃ។ កម្មករគ្រប់គ្នាក្នុងអង្កេតនេះ ជាអ្នកមកពីខេត្ត ក្នុងនោះមាន ៣៨% មកពីព្រៃវែង។ ក្រៅពីប្រាក់កម្រៃ ពួកគេទទួលបានអាហារ និងកន្លែងស្នាក់នៅ ប៉ុន្តែពិបាកនឹងសន្សំប្រាក់បាន ពីព្រោះត្រូវទ្រទ្រង់គ្រួសារនៅឯខេត្ត។

ចំណូលពិតរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៥% ធៀបនឹងអង្កេតលើកមុន មកត្រឹម ៨៣៣៧រៀល/ថ្ងៃ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំង ៤០នាក់ មាន ៥៥% មកពីខេត្តព្រៃវែង និងខ្លះទៀតមកពីខេត្តកណ្ដាល។ ក្នុងចំណោមពួកគេ មាន ៣៥នាក់ មករាជធានីភ្នំពេញជាមួយក្រុមគ្រួសារទាំងមូល។ អ្នករើសអេតចាយទាំងអស់ ត្រូវជួលកន្លែងស្នាក់នៅ និងតែងស្នាក់នៅជាមួយមនុស្ស ៤នាក់ផ្សេងទៀតជាមធ្យម។ ពួកគេមិនមានការងារអ្វីផ្សេងទេ ហើយប្រាក់រកបានអាចដោះស្រាយតម្រូវការចាយវាយបានតែមួយភាគ ដូច្នេះមាន ៧៥% បានខ្ចីប្រាក់គេ។

អ្នកធាក់ស៊ីក្លូរហូតដល់ ៩៥% បានឆ្លើយសម្ភាសន៍ប្រាប់ថា គាត់មកពីខេត្ត ភាគច្រើន ខេត្តព្រៃវែង និងកំពង់ស្ពឺ (២៣% ដូចគ្នា)។ ក្រុមនេះមានប្រាក់ចំណូល ៩៨៦៧រៀល/នាក់/ថ្ងៃ ដែលទាបជាងកាលពីខែឧសភា ដល់ ៨,៣% និងមាន ៩៧,៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ប្រាក់កម្រៃរកបានមិនគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់លើរាល់ចំណាយក្នុងគ្រួសារនោះទេ ដូច្នេះមាន ៦៥% ត្រូវចិញ្ចឹមសត្វ ដូចជាមាន់ទា ដើម្បីរកចំណូលបន្ថែម។ រហូតដល់ ៨៨% នៃអ្នកធាក់ស៊ីក្លូដែលបានឆ្លើយសម្ភាសន៍ ធ្វើដំណើរមករាជធានីភ្នំពេញតែម្នាក់ឯង ហើយត្រូវជួលកន្លែងស្នាក់នៅជាមធ្យមជាមួយមនុស្ស ៣ ឬ ៤នាក់ផ្សេងទៀត។ គាត់ចាយវាយអស់ ៥៦% នៃចំណូលរកបាន ហើយចំណាយលើម្ហូបអាហារ មានចំណែក ៩៤% នៃចំណាយសរុប។

ចំណូលរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៥,៦% ធៀបនឹងខែឧសភា មកត្រឹម ១២.៦៥៦រៀល/ថ្ងៃ។ រហូតដល់ ៩០% នៃអ្នកឆ្លើយសម្ភាសន៍ បានប្រាប់ថា ចំនួនអ្នករត់ម៉ូតូឌុបកើនឡើង រីឯចំនួនអតិថិជននៅថេរដដែល។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ ២០% អាចពឹងផ្អែកលើប្រាក់ចំណូលខ្លួនដើម្បីទ្រទ្រង់គ្រួសារ រីឯ ៨០% ទៀត ត្រូវពឹងផ្អែកលើប្រភពចំណូលដទៃទៀត ជាពិសេសការចិញ្ចឹមមាន់ទានៅផ្ទះ។ ជាមធ្យម ពួកគាត់ចាយវាយអស់ ៤១% នៃប្រាក់ចំណូលរបស់គាត់ ហើយ ចំណាយលើម្ហូបអាហារ មានចំណែក ៩៤% នៃចំណាយសរុប។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាប្រាប់ថា មិនមានសល់ប្រាក់សម្រាប់សន្សំទុកនោះទេ។

ក្នុងចំណោមកម្មកររោងចក្រកាត់ដេរឆ្លើយសម្ភាសន៍ គ្មានអ្នកណាបានបញ្ចប់ថ្នាក់បឋមសិក្សាឡើយ។ ពួកគេទទួលបានកម្រៃ ១១.៣៨៨រៀល/ថ្ងៃ ឬធ្លាក់ចុះ ០,២% ធៀបនឹងអង្កេតលើកមុន។ មានតែ ១១% នៃកម្មករទាំងនោះប៉ុណ្ណោះ ដែលទទួលបានការបណ្ដុះបណ្ដាលជាឯកជន មុនពេលចូលធ្វើការ។ ជាមធ្យមពួកគេបម្រើការក្នុងរោងចក្រកាត់ដេរបច្ចុប្បន្ន បានជាងពីរឆ្នាំមកហើយ រីឯការងារជាក់ស្ដែងគឺ ដេរ និងមុខងារសាមញ្ញៗផ្សេងទៀត ដែលមិនបានផ្ដល់នូវជំនាញសម្រាប់ការរីកចម្រើនក្នុងវិជ្ជាជីវៈឡើយ។ ទោះយ៉ាងណាក្ដី ៥២% នៃកម្មករបានឆ្លើយប្រាប់ថា មិនចង់ផ្លាស់ប្ដូរការងារទេ ហើយ ៤៤% ប្រាប់ថា មិនទាំងដឹងពីការងារអ្វីផ្សេងដែលខ្លួនឯងអាចធ្វើបានផង។

*តពីទំព័រ ១៧* **កំណែទម្រង់វិមជ្ឈការ...**

*Local Rural Governance*. CDRI Working Paper Series No. 94. Phnom Penh: CDRI.

Hughes, Caroline. 2009. *Dependent Communities: Aid and Politics in Cambodia and East Timor*. Ithaca, NY: Cornell Southeast Asia Program.

Kim Sedara. 2012. "Democracy in Action: Decentralization in Post-Conflict Cambodia." PhD dissertation, University of Gothenburg.

Kim Sedara and Joakim Öjendal. 2009. "Decentralization as a Strategy for State Reconstruction in Cambodia." In *Beyond Democracy in Cambodia:Political Reconstruction in a Post-Conflict Society,* edited by J. Öjendal and M. Lilja, 101-135. Copenhagen: NIAS Press.

Malena, Carmen, and Kristina Chhim. 2009. *Linking Citizens and the State: An Assessment of Civil Society Contributions to Good Governance in Cambodia*. Phnom Penh: World Bank Cambodia Country Office.

Martin, Marie Alexandrine. 1994. *Cambodia: A Shattered Society*. Berkeley: University of California Press.

MOEYS, Ministry of Education, Youth and Sport. 2011. *National Policy on Cambodia Youth Development*. Phnom Penh: MOEYS.

NEC, National Election Committee. 2012. "Report on Registered Voters in 2012." Phnom Penh: NEC.

Öjendal, Joakim, and Kim Sedara. 2006. "'Korob, Kaud, Klach': In Search of Agency in Rural Cambodia." *Journal of Southeast Asia Studies* 37(3): 507-526.